**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្តកណ្ដាល

**សំណុំរឿងរដ្ឋប្បវេណី**
លេខ៖ ៣៥៨ រប
ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២៣
សញ្ញាណរឿងក្ដី៖រំលាយកិច្ចសន្យា
សាលក្រមរដ្ឋប្បវេណី
លេខ៖ ៣៨ "ង១"
ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣

## គោរពនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្ដាល

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២៣ ដោយមានសមាសភាពចូលរួមដូចខាងក្រោម:

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមនៃសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្ដាល

**ចេញសាលក្រមដែលមានខ្លឹមសារដូចតទៅ៖**

ដើមចោទ: ក្រុមហ៊ុន សហគ្រិនភាព [redacted] មានទីស្នាក់ការកណ្ដាលនៅផ្ទះ [redacted] តំណាងដោយលោក [redacted] សំបូរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ១៩០២៦៨៨០៦(១) ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦

និងសហចុងចម្លើយ:

១.ឈ្មោះ [redacted] ប៊ុនធឿន ភេទប្រុស កើតថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩១ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ០២០៩០៩២១១ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១២ មានអាស័យដ្ឋាននៅ [redacted] ។

២.ឈ្មោះ [redacted] សុខន ភេទស្រី កើតថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៧៩ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ០២០២៦៨៣៥៥(០១) ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ ដែលមានអាស័យដ្ឋាន [redacted] ។

៣.ឈ្មោះ [redacted] ស៊ីណា ភេទប្រុស កើតថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៥ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ០២០៨៥៥២០៦(០១) ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៨ ត្រូវជាអ្នកធានា ដែលមានអាស័យដ្ឋាន [redacted] ។

តំណាងដោយអាណត្តិ:មេធាវី [redacted] អត្តលេខ:១០០៣ មេធាវី [redacted] អត្តលេខ ២៧២០T និងមេធាវី [redacted] អត្តលេខ:២៧៦៧T។

**កម្មវត្ថុ:**

១.រំលាយកិច្ចសន្យាការងារចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២ ។

២.បង្គាប់ឱ្យសហចុងចម្លើយសងទឹកប្រាក់ចំនួន ១៥៨.០០០.០០០(មួយរយសែសិបបួនលាន)រៀល ស្មើនឹងរយ:ពេល ២៨(ម្ភៃបួន)ខែ ជាចំនួនខែ ដែលសេសសល់ក្នុងកិច្ចសន្យាការងារមានថេរវេលាកំណត់ ។



Scanned with CamScanner

៣.បង្គាប់ឱ្យចុងចម្លើយសងជម្ងឺចិត្ត ការខាតបង់ពេលវេលា ថ្លៃចំណាយសេវាផ្សេងៗចំនួន ៤០.០០០.០០០(សែសិបលានរៀល) ។

៤. ប្រកាសសាលក្រមមានអនុភាពអនុវត្តបណ្ដោះអាសន្នបាន ។

៥.ប្រាក់ប្រដាប់ក្តី និងពន្ធផ្សេងៗជាបន្ទុករបស់សហចុងចម្លើយ ។

បានឃើញ កិច្ចសន្យាការងារ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២ រវាងហាងបញ្ចាំ សហគ្រិនភាព [redacted]តំណាងដោយលោកស្រី [redacted] ធីតា និងឈ្មោះ [redacted] ប៊ុនធឿន។

បានឃើញ លិខិតធានា ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] សុខន និងឈ្មោះ [redacted] ស៊ីណា។

បានឃើញ តារាងត្រួតពិនិត្យ និងបញ្ជាក់ទទួលស្គាល់លើការពន្យល់លក្ខខណ្ឌក្នុងពេលចុះកិច្ចសន្យា។

បានឃើញ លិខិតបញ្ជាក់ពីភាពច្បាស់លាស់អំពីគោលការណ៍នីតិវិធីសេចក្តីសម្រេចផ្សេងៗ។

បានឃើញ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ:០២០៩០៩២១១ របស់ឈ្មោះ [redacted] ប៊ុនធឿន។

បានឃើញ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ:០២០២៦៨៣៥៥ (១) របស់ឈ្មោះ [redacted] សុខន។

បានឃើញ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ:០២០៨៥៥២០៦ (១) របស់ឈ្មោះ [redacted] ស៊ីណា។

បានឃើញអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ:១៩០២៦៨៨០៦ (១)របស់ឈ្មោះ [redacted] សំបូរ។

**អង្គហេតុ និងចំណុចវិវាទ**

១.សាលក្រមដែលទាមទារដោយដើមចោទ:

១.១-រំលាយកិច្ចសន្យាការងារចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២ ។

១.២-បង្គាប់ឱ្យសហចុងចម្លើយសងទឹកប្រាក់ចំនួន ១៤៤.០០០.០០០(មួយរយសែសិបបួនលាន)រៀល ស្មើនឹងរយៈពេល ២៤ (ម្ភៃបួន) ខែជាចំនួនខែដែលសេសសល់ក្នុងកិច្ចសន្យាការងារមានថេរវេលាកំណត់ ។

១.៣-បង្គាប់ឱ្យចុងចម្លើយសងជម្ងឺចិត្ត ការខាតបង់ពេលវេលា ថ្លៃចំណាយសេវាផ្សេងៗចំនួន ៤០.០០០.០០០(សែសិបលានរៀល) ។

១.៤- ប្រកាសសាលក្រមមានអនុភាពអនុវត្តបណ្ដោះអាសន្នបាន ។

១.៥-ប្រាក់ប្រដាប់ក្តី និងពន្ធផ្សេងៗជាបន្ទុករបស់សហចុងចម្លើយ ។

២. ការពន្យល់ត្រួសៗអំពីរឿងក្តី

កាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២ ក្រុមហ៊ុន [redacted] បានចុះកិច្ចសន្យាការងារមានកំណត់រយៈថេរវេលា ជាមួយភាគីចុងចម្លើយឈ្មោះ [redacted] ប៊ុនធឿន នៅក្នុងមុខតំណែងជាអនុប្រធាននាយកដ្ឋានជ្រើសរើសបុគ្គលិកប្រចាំការិយាល័យកណ្តាល។ ក្នុងមុខដំណែងនេះភាគីចុងចម្លើយទទួលបានប្រាក់បៀវត្សប្រចាំខែចំនួន ៦.០០០.០០០(ប្រាំមួយលាន)រៀល។ តាមរយៈកិច្ចសន្យាការងារមានកំណត់ថេរវេលា ភាគីចុងចម្លើយ បានព្រមព្រៀងបម្រើការងារជាមួយក្រុមហ៊ុនរយៈពេលកំណត់ចំនួន ០២(ពីរ) ឆ្នាំ ដែលស្មើនឹង ២៤(ម្ភៃបួន) ខែ ដោយត្រូវបំពេញការងារគិតចាប់ពីថ្ងៃ០៣ ខែតុលា ឆ្នាំ២០២២ ដល់ថ្ងៃទី០២ ខែតុលា ឆ្នាំ២០២៣។ ដោយមិនទាន់ដល់កំណត់នៃថ្ងៃបញ្ចប់កិច្ចសន្យាការងារ ភាគីចុងចម្លើយបានបំពានកិច្ចសន្យាដោយឯកតោភាគី ដោយ



Scanned with CamScanner

មិនបានមកបម្រើការងារទៅតាមការព្រមព្រៀងឡើយ (រត់ចោលការងារ)។ ទោះបីជាភាគីក្រុមហ៊ុនបានព្យាយាមទំនាក់ទំនងដើម្បីជួបដោះស្រាយដោយសន្តិវិធីជាច្រើនលើកច្រើនសារជាមួយសហចុងចម្លើយក៏ដោយ ក៏ចុងចម្លើយតែងតែគេចវេស និងមិនអើពើឡើយ។

៣. ចំណុចវិវាទ

- តើការទាមទាររបស់ដើមចោទមានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់ដែរឬទេ?
- តើភាគីចុងចម្លើយពិតជាមិនបានអនុវត្តកាតព្វកិច្ចនៃកិច្ចសន្យាមែនដែរឬទេ?

## សំអាងហេតុ

១. ការទាមទាររបស់ដើមចោទមានលក្ខណៈត្រឹមត្រូវតាមទម្រង់ច្បាប់ អាចឲ្យតុលាការលើកយកមកពិចារណាបាន ។

២. ដើមចោទឈ្មោះ [redacted] សំបូរ បានធ្វើសេចក្តីថ្លែងការណ៍ថាៈកាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២ ក្រុមហ៊ុនរបស់ខ្លួនបានចុះកិច្ចសន្យាផ្តល់ការងារជាមួយភាគីចុងចម្លើយឈ្មោះ [redacted] ប៊ុនធឿន នៅក្នុងមុខតំណែងជាអនុប្រធាននាយកដ្ឋានជ្រើសរើសបុគ្គលិក ប្រចាំការិយាល័យកណ្តាល ក្នុងមុខតំណែងនេះដែរភាគីចុងចម្លើយបានទទួលប្រាក់បៀវត្សន៍ ប្រចាំខែចំនួន ៦.០០០.០០០(ប្រាំមួយលាន)រៀល។ តាមរយៈកិច្ចសន្យាការងារខាងលើ ភាគីចុងចម្លើយបានព្រមព្រៀងចុះកិច្ចសន្យាមានថិរវេលាកំណត់មានរយៈពេល ០២ឆ្នាំដែលស្មើនឹង ២៤ខែ ជាមួយក្រុមហ៊ុន។ ប៉ុន្តែមិនទាន់ដល់ពេលកំណត់នៃកិច្ចសន្យាបែរជាភាគីចុងចម្លើយបានរំលោភកិច្ចសន្យាការងារ ដោយមិនបានមកបម្រើការងារតាមការព្រមព្រៀងក្នុងកិច្ចសន្យាការងារ។ បើទោះបីជាខាងក្រុមហ៊ុនខ្លួនបានព្យាយាមទំនាក់ទំនង ក៏សហចុងចម្លើយមិនអើពើនោះដែរ។ មុននឹងឈានដល់ការដាក់ពាក្យបណ្តឹងនេះ ខាងក្រុមហ៊ុនបានព្យាយាមដោះស្រាយដោយសន្តិវិធី រួចរាល់ហើយ បើទោះបីជាខាងក្រុមហ៊ុនក្តី ឬតាមរយៈមេធាវីក្តី ក៏ប៉ុន្តែនៅតែមិនទាន់ទទួលបានលទ្ធផលណាមួយឡើយដោយសារតែសហចុងចម្លើយតែងតែគេចវេស ។ ហេតុដូច្នេះ ទើបក្រុមហ៊ុនសម្រេចចិត្តដាក់ពាក្យបណ្តឹងតាមផ្លូវច្បាប់មកសាលាដំបូងដើម្បីដោះស្រាយ និងការពារផលប្រយោជន៍ស្របច្បាប់របស់ក្រុមហ៊ុន។

៣. លោកមេធាវី [redacted] និងលោកមេធាវី [redacted] បានថ្លែងការណ៍ថាៈ នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២ កូនក្តីរបស់ខ្លួនឈ្មោះ [redacted] ប៊ុនធឿន បានចុះកិច្ចការងារដែលមានកំណត់ថេរវេលាជាមួយក្រុមហ៊ុន សហគ្រិនភាព [redacted] លីមីតធីត មានស្នាក់ការកណ្តាល [redacted] ដោយក្នុងការចុះកិច្ចសន្យាការងារនេះមានតួនាទីជាអនុប្រធាននាយកដ្ឋានជ្រើសរើសបុគ្គលិកប្រចាំការិយាល័យកណ្តាល ដែលមានរយៈពេល ០២ (ពីរ) ឆ្នាំ គិតចាប់គិតពីថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី០២ ខែតុលា ឆ្នាំ២០២៤ ដោយនឹងទទួលបានប្រាក់បៀវត្សជាប្រចាំខែចំនួន ៦,០០០,០០០ (ប្រាំមួយលាន) រៀល។

ដោយហេតុថា នៅថ្ងៃចុះកិច្ចសន្យាការងារភាគីខាងក្រុមហ៊ុន សហគ្រិនភាព អេសធីអេសខេ លីមីតធីត មិនបានទុកពេលវេលា និងមិនបានផ្តល់ទីកន្លែងសមរម្យ សម្រាប់ការពិភាក្សាគ្នាហើយទីតាំងជួបពិភាក្សាគ្នាបន្ទប់បុគ្គលិកធ្វើការទូទៅដែលមានបុគ្គលិកប្រមាណ ៦ ទៅ ៧នាក់



Scanned with CamScanner

កំពុងតែធ្វើការដែលមិនមានភាពស្ញប់ស្ញាត់សម្រាប់ឱ្យកូនក្តីរបស់ខ្លួនបានពិនិត្យ និងអានអំពីខ្លឹមសារដែលមានក្នុងលក្ខខណ្ឌដូចបានចែងក្នុងកិច្ចសន្យាការងារទាំងមូលឱ្យបានយល់ច្បាស់ រួមទាំងចរចារលក្ខខណ្ឌណាមួយជាមួយក្រុមហ៊ុនឡើយ គឺដល់ថ្ងៃណាត់ជួបពិភាក្សាគ្នាតម្រូវឱ្យកូនក្តីរបស់ខ្លួនផ្តិតមេដៃលើកិច្ចសន្យាការងារតែម្តង ដោយការផ្តិតតែម្ខាងជាឯកតោភាគី ដែលខាងក្រុមហ៊ុនមិនទាន់បានចុះហត្ថលេខា ឬផ្តិតមេដៃនៅឡើយ។ម្យ៉ាងវិញ នៅពេលដែលកូនក្តីរបស់ខ្លួនចុះកិច្ចសន្យារួចហើយ ភាគីខាងក្រុមហ៊ុន សហគ្រិនភាព [redacted] មិនព្រមប្រគល់កិច្ចសន្យាការងារច្បាប់ដើម ឬឯកសារថតចម្លងណាមួយប្រគល់មកកាន់កូនក្តីខ្លួនឡើយ ដោយយកហេតុផលនេះហេតុផលនោះ ឬថាលោកស្រី [redacted] ធីតា ជាប្រធានការិយាល័យប្រតិបត្តិមិននៅការិយាល័យ។

បន្ទាប់ពីចុះកិច្ចសន្យារួចហើយ កូនក្តីរបស់ខ្លួន យល់ឃើញថា កិច្ចសន្យាការងារដែលខ្លួនបានផ្តិតមេដៃរួចហើយនោះ មានភាពកេងចំណេញហួសហេតុពេក និងផ្ទុយពីបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ ទើបកូនក្តីរបស់ខ្លួន បានធ្វើការជូនដំណឹងនៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ ទៅលោកស្រី សុង កញ្ញាភ័រត្តី ជាមន្ត្រីជ្រើសរើសបុគ្គលិកជាន់ខ្ពស់ តាមរយៈទូរស័ព្ទលេខ ០១៥ ៧៨៥ ១៦៥ ស្តីពីការសុំមិនចូលបម្រើការងារជាមួយក្រុមហ៊ុនទេ លុះមកដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ២០២២ កូនក្តីរបស់ខ្លួនបានទទួលដំណឹងពីលោក ស្រៀល សំបូរ បានព្យាយាមទាមទារសំណងជម្ងឺចិត្ត និងសំណងការខូចខាតចំនួន ០១ខែទៅ ០១ខែកន្លះ (ប្រាក់ខែគោលចំនួន ៦,000,000 (ប្រាំមួយលាន) រៀលក្នុងមួយខែ) ទាំងដែលកូនក្តីរបស់ខ្លួនមិនទាន់បានចូលធ្វើការងារនៅក្នុងក្រុមហ៊ុន និងមិនបានបង្ករព្យសនកម្មដល់ក្រុមហ៊ុននៅឡើយ។

បន្ទាប់មកនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២២ ភាគីខាងក្រុមហ៊ុន សហគ្រិនភាព[redacted] លីមីតធីត តំណាងដោយលោក[redacted]សុភារ៉ា បានដាក់ពាក្យបណ្តឹងប្តឹងកូនក្តីរបស់ខ្លួននៅសាលាឃុំព្រែកដាច់ ដោយភ្ជាប់ឯកសារកិច្ចសន្យាការងារដោយមិនមានចុះហត្ថលេខា លោកស្រី[redacted] ធីតា និងប្រថាប់ត្រារបស់ក្រុមហ៊ុនឡើយ ដូចមានការបញ្ជាក់របស់លោកមេឃុំព្រែកដាច់ (ដូចមានបញ្ជាក់ក្នុងឯកសារច្បាប់ដើមចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២៣) ពិតជាមិនមានចុះហត្ថលេខា និងត្រារបស់ក្រុមហ៊ុនពិតប្រាកដមែន ទើបតែមកដល់តំណាក់កាលដាក់ពាក្យបណ្តឹងនៅសាលាដំបូងខេត្តកណ្តាល ទើបមានហត្ថលេខារបស់លោកស្រី[redacted] ធីតា ជាប្រធាននាយិកាប្រតិបត្តិ។

ដូច្នេះក្នុងនាមកូនក្តីខ្លួន សូមឆ្លើយតបនឹងកម្មវត្ថុនៃការទាមទាររបស់ដើមចោទដូចខាងក្រោម:

១-ចំណុចទី១ នៃកម្មវត្ថុនៃការទាមទារ:ខ្លួនឯកភាពក្នុងការរំលាយកិច្ចការងារ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២។

២-ចំណុចទី២ នៃការទាមទារៈខ្លួនសុំច្រានចោលការឲ្យសងទឹកប្រាក់ចំនួន ១៤៤,000,000 (មួយរយសែសិបបួនលាន) រៀល ស្មើនឹងរយៈពេលចំនួន ២៤ (ម្ភៃបួន) ខែជាចំនួនសេសសល់ក្នុងកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ដោយសារ កិច្ចសន្យាការងារនេះមិនមានអនុភាពអនុវត្តនៅឡើយ និងផ្ទុយពីច្បាប់ការងារឆ្នាំ១៩៩៧ យោងតាមមាត្រា ៣១០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ "និយមន័យនៃការបង្ហាញឆន្ទៈ" មាត្រា ៣១១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ "និយម



Scanned with CamScanner

ន័យនៃកិច្ចសន្យា" មាត្រា ៣៣៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ "ការបង្កើតកិច្ចសន្យា" មាត្រា ៣៩៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ "អំពើកេងចំណេញហួសហេតុ" មាត្រា ៧០ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ និងមាត្រា ៨២ នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧។

៣-ចំណុចទី៣ នៃកម្មវត្ថុនៃការទាមទារៈខ្លួនស្នើសុំច្រានចោលការឲ្យសងសំណងជម្ងឺចិត្ត ការខាតបង់ពេលវេលា ថ្លៃចំណាយសេវាកម្មផ្សេងៗ ចំនួន ៥០,០០០,០០០ (សែសិបលាន) រៀល ដោយសារកូនក្តីរបស់ខ្លួនមិនទាន់បានបម្រើការងារ និងមិនបានបង្កព្យសនកម្មដល់ក្រុមហ៊ុននៅឡើយទេ។

៤-ចំណុចទី នៃកម្មវត្ថុនៃការទាមទារៈខ្លួនសុំច្រាលចោលការប្រកាសសាលក្រមមានអនុភាពអនុវត្តបណ្តោះអាសន្ន។

៥-ចំណុចទី៥ នៃកម្មវត្ថុនៃការទាមទារៈចំពោះប្រាក់ប្រដាប់ក្តី និងពន្ធផ្សេងៗជាបន្ទុករបស់ដើមចោទ។

៤- ដើមចោទឈ្មោះ សហគ្រិនភាព [redacted] លីមីតធីត បានសុំរំលាយកិច្ចសន្យាការងារ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២ រវាង ក្រុមហ៊ុន [redacted] លីមីតធីត និងឈ្មោះ [redacted] ប៊ុនធឿន,បង្គាប់ឱ្យសហចុងចម្លើយសងទឹកប្រាក់ចំនួន ១៩៥.០០០.០០០(មួយរយសែសិបបួនលាន)រៀល ស្មើនឹងរយៈពេល ២៤ (ម្ភៃបួន) ខែជាចំនួនខែ ដែលសេសសល់ក្នុងកិច្ចសន្យាការងារមានថេរវេលាកំណត់,បង្គាប់ឱ្យចុងចម្លើយសងជម្ងឺចិត្ត ការខាតបង់ពេលវេលា ថ្លៃចំណាយសេវាផ្សេងៗចំនួន ៥០.០០០.០០០(សែសិបលាន)រៀល)។

តាមមាត្រា ៧៣ នៃច្បាប់ស្តីពីការងារ ដែលរដ្ឋសភាពបានអនុម័តកាលពីថ្ងៃទី១០ ខែមករា ឆ្នាំ១៩៩៧ នាសម័យប្រជុំលើកទី៧ នីតិកាលទី១ កថាខណ្ឌទី៤ បានចែងថា "ការរំលាយកិច្ចសន្យាដោយឆន្ទៈរបស់កម្មករនិយោជិតតែឯកឯង ក្រៅពីមូលហេតុដែលបានចែងក្នុងកថាខ័ណ្ឌទី ១ និងទី ២ នៃមាត្រានេះបើកសិទ្ធិអោយនិយោជកទទួលជំងឺចិត្តស្មើនឹងការខូចខាតរបស់ខ្លួនដែលបានផ្តល់អោយកម្មករនិយោជិត។

តុលាការយល់ថា ក្រុមហ៊ុន សហគ្រិនភាព [redacted] និងឈ្មោះ [redacted] ប៊ុនធឿន បានធ្វើការព្រមព្រៀងបង្កើតកិច្ចសន្យាការងារដែលមានកំណត់ថិរវេលាដែលមានរយៈពេល ០២ (ពីរ) ឆ្នាំ ដោយចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២២ ដល់ថ្ងៃទី០២ ខែតុលា ឆ្នាំ២០២៤ ប៉ុន្តែនៅពេលដែលដល់ថ្ងៃកំណត់អនុវត្តការងាររបស់ខ្លួនឈ្មោះ [redacted] ប៊ុនធឿន មិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនឡើយ និងបានស្នើសុំរំលាយកិច្ចសន្យា ដោយមិនមានការព្រមព្រៀងពីភាគីម្ខាងទៀតនៃកិច្ចសន្យា នេះជាការរំលាយកិច្ចសន្យាដោយឯកឯង។ គប្បីតុលាការពិចារណា និងសម្រេច។

## សេចក្តីសម្រេចបញ្ចប់

១- រំលាយកិច្ចការងារ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២ រវាង ក្រុមហ៊ុន [redacted] លីមីតធីត និងឈ្មោះ [redacted] ប៊ុនធឿន។



Scanned with CamScanner

២- បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] ប៊ុនធឿន សងប្រាក់ទៅ ក្រុមហ៊ុន [redacted] លីមីតធីត ចំនួន ១៤៤,០០០,០០០ (មួយរយសែសិបបួនលាន) រៀល ចំពោះចំនួនខែដែលនៅសល់ក្នុងកិច្ចសន្យាការងារមានថិរវេលាកំណត់។

៣- បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] ប៊ុនធឿន សងសំណងជម្ងឺចិត្តចំនួន ១៥,០០០,០០០ (ដប់ប្រាំលាន) រៀល ទៅឱ្យដើមចោទ ក្រុមហ៊ុន [redacted] លីមីតធីត។

៤-ច្រានការចោលការទាមទាររបស់ដើមចោទត្រង់ចំណុចទី៤ ប្រកាសសាលក្រមមានអនុភាពអនុវត្តបណ្ដោះអាសន្នបាន។

៥- ប្រាក់ប្រដាប់ក្តី និងប្រាក់ប្រដាប់ក្ដីក្រៅពន្ធ ជាបន្ទុករបស់ចុងចម្លើយ។

សាលក្រមនេះទាញហេតុផលផ្ទាល់មាត់នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣ ចំពោះមុខដើមចោទ និងចំពោះមុខចុងចម្លើយ។

ទុកសិទ្ធិឲ្យគូភាគីប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

កណ្ដាល,ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

បានឃើញ

**ចៅក្រម**

[redacted]

"បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

កណ្ដាល,ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner